# Sangkum Thmey

Cambodian American League of Lowell Vol. 1 June1997


## From the Executive Director



**Dear Friends:**

Sangkum Thmey means "New Community" in Khmer and is the name of this newsletter which is being published by the Cambodian American League of Lowell. Our goal is to inform the community of the news of interest important to them. Sangkum Thmey will be published in both English and Khmer and will be distributed free of charge. News published in this newsletter is divided into three areas: local news, business news, and news from Cambodia.

We welcome your comments and suggestions for this newsletter. Your contributions of both news articles and financial underwriting are greatly needed and appreciated. We wish to thank the Massachusetts Office for Refugees and Immigrants, CALL's Board of Directors, the Microenterprise Advisory Committee, the Loan Committee, Bunrith Sath, Sunny Leang, Enterprise Bank and Trust Company, and the International Institute for making this newsletter a reality. We also wish to thank our funders who include the city of Lowell, the Department of Housing and Community Development, the Parker Foundation, The Lindsay Trust, BankBoston, Family Bank, and MassBank.

Ratha Paul Yem
Executive Director

## ស្វាគមន៍លោកលោកស្រីអ្នកនាងកញ្ញា និងមិត្តអ្នកអានជាទីមេត្រី !

ព្រឹត្តិប័ត្រសង្គមថ្មីរៀបចំឡើងដើម្បីផ្តល់ព័ត៍មានសំខាន់ៗនិង មានសារប្រយោជន៍ដលមិត្តអ្នកអានទាំងអស់ពិសេសព័ត៍មាន ទាក់ទងនឹងរឿង ពាណិជ្ជកម្ម, ព័ត៍មានកើតឡើងក្នុងសង្គមខ្មែរ យើងនិងព័ត៍មានមកពីប្រទេសខ្មែរ។ ព្រឹត្តិប័ត្រនេះ នឹង បោះពុម្ភផ្សាយរឿងរាល់ខែជាភាសា ខ្មែរ និង ភាសាអង់គ្លេសហើយនិងចែកជូនលោក លោកស្រី និងប្រិយមិត្តអ្នកអានដោយឥតគិតថ្លៃ។

យើងខ្ញុំស្វាគមន៍នូវការរិះ គន់ដើម្បីជួយ កសាងនិងជំនួយជាវិភាគទានពីសំណាក់មិត្តអ្នកអាន គ្រប់ពេលវេលា។ សូម អញ្ជើញទាក់ទងមកយើងខ្ញុំ ដោយមេត្រីភាព បើលោក/លោកស្រី និងមិត្តអ្នកអានមានសំណូមពរយ៉ាងណាស្តីពីព្រឹត្តិប័ត្រយើង។

យើងខ្ញុំ សូមថ្លែងអំណរគុណដល់គណៈកម្មាធិការនាយកនៃ សហគមន៍ខ្មែរអាមេរីកាំង; ការិយាល័យរដ្ឋខាងអនិកជននិង ជនភៀសខ្លួនដែលបានផ្តល់ជំនួយក្នុងការ បោះពុម្ភផ្សាយព្រឹត្តិ ប័ត្រនេះ; ការិយាល័យ អ៊ិនឌូឆាយ ណា; លោក លៀងសាន់នី និងលោកសាធប៊ុនរិទ្ធដែល ជួយសរសេរ និងរៀបចំព្រឹត្តិប័ត្រ ទាំងមូល; ធនាគារអ៊ិនទ័រប្រាយដែលជួយផ្តល់ អត្ថបទសំរាប់ ព្រឹត្តិប័ត្រយើង។

សូមអរគុណ។

# What's new(s)?

## Cambodian American League of Lowell

*****************

The Cambodian American League of Lowell (CALL) was founded in 1993 as a Community Development Corporation (CDC) in response to the absence of targeted economic development assistance to Lowell's Cambodian and other Southeast Asian communities. Its primary focus is to strengthen and expand local businesses and to promote home ownership among Southeast Asian immigrants in the Lower Highlands neighborhood and throughout the City. Presently, CALL offers the following programs :

សហគមន៍ខ្មែរអាមេរិកកាំងប្រចាំទីក្រុងឡូវែល មានដើមកំណើតក្នុងឆ្នាំ១៩៩៣ ហើយជាក្រសួងវឌ្ឍនកម្មប្រចាំសហគមន៍មួយដែលចូលខ្លួនមកដើម្បីឆ្លើយតបនូវសេចក្តីត្រូវការផ្នែក ខ្វះខាតជំនួយវឌ្ឍនកម្មនៃសេដ្ឋកិច្ច ដល់ជនជាតិខ្មែរក្រុងឡូវែល និងសហគមន៍ជនជាតិអាស៊ីភាគអគ្នេយ៍ទាំងមូល។ គោលបំណងដ៏ចំបងនៃសហគមន៍ក្រុងឡូវែលគឺចង់ពង្រឹងពង្រីកហាងជំនួញនានាក្នុងតំបន់ និងជួយរកវិធីទិញផ្ទះ ដល់អស់លោក-អ្នកនាង ជាជនជាតិខ្មែរ និងជនជាតិអាស៊ីភាគអគ្នេយ៍ ដែលរស់នៅក្នុងតំបន់ Loweller Highlands និងទូទាំងទីក្រុងទាំងមូល។

## CITIZENSHIP PROJECT




Citizenship Project provides assistance to Cambodian refugees and immigrants who are interested in becoming an American Citizen especially people who are 55 years and older. This project includes outreach in the Highlands and other neighborhoods with high concentrations of Southeast Asian residents through fliers, announcements on the local Cambodian TV and radio; compiling training materials in both English and Khmer in writing and on audio cassetts; and preparation classes.

**កម្មវិធីចូលសញ្ជាតិ:**

កម្មវិធីនេះមានការបង្ហាត់បង្ហាញដល់ជនភៀសខ្លួនខ្មែរ និងជនអន្តោប្រវេសន៍ ដែលចង់ក្លាយជាសញ្ជាតិអាមេរិកកាំង ហើយមានអាយុចាប់តាំងពី៥៥ឆ្នាំឡើងទៅ។ ជាមួយគ្នានេះផងដែរ គឺយើងធ្វើការទំនាក់ទំនងក្នុងតំបន់ Highlands និងតាមតំបន់នានាក្នុងសហគមន៍អាស៊ីភាគអគ្នេយ៍ តាមរយៈការនែនាំ,ក្រដាស់បិទផ្សាយ,ទូរទស្សន៍,និងតាមរយៈការផ្សាយនៃវិទ្យុសម្លេងខ្មែរ។ ថ្នាក់បង្រៀន និងក្រដាស់ស្នាមផ្សេងៗ គឺសុទ្ធតែបកប្រែជាខ្មែរភាសាអង្គេសនិងខ្មែរ និងមានជាកាសែតខ្សែភាត់ទៀតផង។

## HOME BUYING EDUCATION AND ASSISTANCE



First Time Homebuying Seminar is a collaboration CALL and the Merrimack Valley Housing Partnership (MVHP) started in November, 1995. The seminar is offered quarterly since and more than one hundred Southeast Asian families, the majority of them are Cambodians, finished this training. About ten families have already purchased their homes.

Homeownership Education and Assistance also provides additional service such as follow-up after first time homebuying seminars, down payment assistance, home buying assistance, and other assistance necessary to become a home owner.

**កម្មវិធីបង្ហាត់ជួយរកទិញផ្ទះ:**

-កម្មវិធីជួយរកទិញផ្ទះជាលើកដំបូង សហគមន៍ខ្មែរអាមេរិកាំងសហការនិងក្រសួង Merrimack Valley Housing Partnership (MVHP) ហើយមានកំណើតតាំងពីខែវិច្ឆកាឆ្នាំ១៩៩៥។ ថ្នាក់បង្ហាត់បានបើកបង្រៀនបួនដងមួយឆ្នាំ ហើយមានសិស្សជនជាតិអាស៊ីភាគអគ្នេយ៍ជាង១00នាក់បានមកចូលរួម ចំនួនភាគច្រើនជាងគេ គឺជនជាតិខ្មែរយើង ដែលបានរៀននិងហ្វឹកហ្វឺនចប់សព្វគ្រប់។ ប្រហែលជា១0គ្រួសារមកហើយដែលទិញផ្ទះ។

កម្មវិធីជួយរកទិញផ្ទះ ក៏ជួយផ្តល់នូវជំនួយដល់អស់លោកអ្នកនាង ដូចជា ការសម្រួលកិច្ចការផ្សេងៗទាក់ទងនិងការទិញផ្ទះជាលើកទីមួយ,ជួយរកប្រាក់ថ្លៃកក់,រកប្រាក់ជំនួយទិញផ្ទះ,និងធុរះសំខាន់ផ្សេងៗទៀតដែលលោកអ្នកត្រូវការ ដើម្បីក្លាយជាម្ចាស់ផ្ទះម្នាក់។

## YOUTH ANTI-VIOLENCE PROJECT




CALL in conjunction with three other youth programs: Big Brother/Big Sister, Lowell Teen Coalition and the City Streetworkers Program is developing PSAs, is producing a ten minute video, and a poster contest with anti-violence messages. The project is developed and carried out by a group of fifteen peer leaders who were selected from a pool of about 200 young people.

**កម្មវិធីយុវវ័យប្រឆាំងអំពើឃោរឃៅ:**

សហគមន៍ខ្មែរអាមេរិកាំងប្រចាំក្រុងឡូវែល ធ្វើសហការជាមួយយុវវ័យបីក្រុម: Big Brother/Bis Sister, Lowell Teen Coalition និង City Streetworkers។ កម្មវិធីនេះកំពុងបង្កើតនូវខ្សែវិឌីអូរ និងមានការប្រឡងប្រជែងនូវការគូរគំនូរ ជារូបភាពដែលបង្ហាញពីការប្រឆាំងអំពើឃោរឃៅ។ មានយុវវ័យ១៥នាក់ ជាអ្នកដឹកនាំកម្មវិធី ហើយត្រូវបានធ្វើការជ្រើសរើសពីចំណោមយុវវ័យ២00នាក់។

## MICROENTERPRISE TRAINING AND LOAN FUND



This program is a three year collaboration between CALL and Jewish Vocational Service of Boston which began in the Fall of 1995. This program is targeted refugees who live in Greater Lowell and who are either business owners or are interested in starting their own businesses. This program graduated 20 entrepreneurs, 8 of whom have already started a business. The microenterprise training is offered twice a year and focuses on business planning, cash flow, and marketing, etc.

## ★★★★★របៀបទិញផ្ទះ★★★★

ការទិញផ្ទះ គឺជាពេលមួយដែលសប្បាយរីករាយសំរាប់ជីវិតមនុស្ស ។ ផ្ទះមួយ យើងត្រូវចំណាយនូវថវិការច្រើន និងត្រូវជ្រើសរើសការបណ្តាក់ទុន ហើយការចំណាយផ្សេងៗទៀត អាចធ្វើឲ្យការរកទិញផ្ទះមានបន្ទុកច្រើនប្រការ ។ ចំណុចខាងក្រោមនេះអាចជួយលោកអ្នកនាងមុនពេលលោកអ្នកនាង ដើររកទិញផ្ទះ ។ សង្ឃឹមថាកម្រងការរកទិញផ្ទះនេះ និងជួយសម្រួលលោកអ្នកនាង ក្នុងការរកទិញផ្ទះមិនខាន ។



<>>បង្កើតបំណងនិងគ្រោងថវិការ(ចំណាយ):

★ ធ្វើការសំរេចនិងគិត ពីខ្នាត,ម៉ាកផ្ទះរបៀបណា ដែលចង់ទិញ ។

★គ្រោងថវិការ(ចំណាយ)គិតកំណត់ពីចំនួនទឹកលុយដែលយើងធ្វើកាដែលអាចដាក់ចូលក្នុងគណនីប្រាក់សន្សំបាន ។

★ បង្កើតប្រវត្តិ Credits ឲ្យល្អ:

★ ប្រវត្តិគ្រីឌិតល្អ អាចកើតកើនដោយ: បង់ផ្ទះ និងបង់ថ្លៃទឹក,ភ្លើង,ឧស្ម័ន ឲ្យទៀង ទាត់ពេល ។

★ បង្កើតប្រវត្តិគណនីប្រាក់សន្សំល្អ ។



<<>>ការរកខ្ចីប្រាក់ទិញផ្ទះ:

★ កំណត់ចំនួនទឹកលុយដែលចង់ខ្ចីមកទិញផ្ទះ ពិភាគសាជាមួយក្រសួងផ្តល់ដំបូន្មាន,ធនាគារក្រុងឡូវែលអាចជួយសំរេចចិត្ត ក្នុង រឿងនេះ ។



★ ធនាគារភាគច្រើន និងក្រសួងឲ្យខ្ចីប្រាក់ទិញផ្ទះច្រើនតម្រូវឲ្យមានប្រាក់កក់ប្រាំភាគរយនៃតម្លៃថ្លៃលក់ (5% down payment of the sales price)។

★ នៅក្នុងក្រុងឡូវែលយើង មានកម្មវិធីអាចជួយ រក ប្រាក់កក់ជូនលោក អ្នកនាងបាន ។

<<>>ការរកទិញផ្ទះមួយ:

★ ឈ្មួញកណ្តាលដែលជាអ្នកទិញលក់ដីនិងផ្ទះ និងពន្យល់បង្ហាញផ្ទះជាច្រើន ឲ្យលោក អ្នកនាងធ្វើការជ្រើសរើស ។

★ ព្រឹត្តិប័ត្រ,ទស្សនវដ្តីឬសៀវភៅផ្សព្វផ្សាយផ្សេងៗ យើងមានអ្នកអាចជួយឲ្យយោបល់ ។

<<>>ការឲ្យតម្លៃ និង ចុះហត្ថលេខាកិច្ចព្រមព្រៀង ថ្លៃទិញ និងលក់

★ ត្រូវមានមេធាវីយ៉ាងហោចម្នាក់ជាផ្លូវការក្នុងថ្ងៃចុះហត្ថលេខាលើកិច្ចព្រមព្រៀង ថ្លៃទិញ និង លក់

★ ក្នុងលិខិតកិច្ចព្រមព្រៀងថ្លៃទិញ និងលក់ត្រូវមានការបម្រុងទុកជាមុន នូវប្រាក់សម្រាប់ប្រើប្រាស់សម្រាប់ ការពារពេល ខ្ចីប្រាក់មិនបាន។ ចំណុចនេះៈជាកិច្ចងាយស្រួលក្នុងការ យកប្រាក់ថ្លៃកក់សំណុំរឿងខ្ចីប្រាក់ទិញផ្ទះ

★ សំណុំរឿងត្រូវយកពីធានាគាហើយបំពេញផ្ញើរទៅគេវិញ

★ ពេលណាសំណុំរឿងបានទទួលចប់សព្វគ្រប់,ការជ្រើសរើសថ្ងៃកាត់ឈ្មោះនិងកំណត់តាមពេលវេលា

<<>>ថ្ងៃកាត់ឈ្មោះ

★ អ្នកទិញផ្ទះនិងអ្នកលក់មកជួបជុំគ្នាដោយនាំមកនូវមេធាវីរៀងៗខ្លួនផងដែរ។

★ កិច្ចព្រមព្រៀងគឺត្រូវប្តូរពីអ្នកលក់ទៅអ្នកទិញហើយត្រូវកត់ត្រាដោយមេធាវី។

<< ថ្ងៃនេះហើយជាថ្ងៃដែលលោកអ្នកក្លាយជាម្ចាស់ផ្ទះ >>

C.A.L.L. Inc.
*Bringing people together*

**OFFICERS**

**PRESIDENT**
Tom Seng

**VICE-PRESIDENT**
Vesna Nuon

**SECRETARY**
Jim Wild

**TREASURER**
Germaine Vigeant

**BOARD OF DIRECTORS**
Lyla Chea
Robert Doland
Sausalina Lay
Sothara Ly
Kenneth Masson
Heng Meas
Kem Men
Kathy muldoon
Barry Pearson
Im Sok
George Tucker

**EXECUTIVE DIRECTOR**
Ratha Paul Yem

**BUSINESS OUTREACH COORDINATOR**
Ith Lunn

**CITIZINSHIP PROGRAM COORDINATOR**
Sidney Liang




# The Homebuying process

The process of buying a home is one of the most exciting times in a person's life. A home is one of the most expensive and important investments you will make and because of the expense, the process can be ovewhelming. Here are a few things to do before begining the search for a home. Hopefully they will make the process a little more enjoyable.



**Establish Goals and Budget:**

{a} Determine the type of home you wish to buy

{b} Establish the budget

- determine the amount of your paycheck that you can afford to put in your saving account.
- this will help when applying for a mortgage loan

**Establish a good Credit History:**

{a} Credit histry can be established by paying rent and utility bills on time.

{b} Through a saving history.

**Obtaining a Mortgage:**

{a} Determine the amount of mortgage you qualified for.

- There are counseling agencies/banks in Lowell to help determine this.

{b} Most banks and mortgage companies require a minimum down payment of 5% of the sales price.

- There are programs available in Lowell for down payment assistance.

**Shopping for a Home:**

{a} Real estate brokers will provide the widest selection of homes.

{b} Newspapers or brochures can also be consulted

**Making an Offer and Signing a Purchase and Sale Agreement:**

{a} An attorney should be consulted before signing any purchase and sale agreement.

{b} The purchase and sale agreement should contain a financing contingency in the event a mortgage loan cannot be obtained. This ensures the return of the real estate deposite.

**Mortgage Application:**

{a} A formal application should be submitted to the bank for financing.

{b} Once the application has been process and approved, the closing date will be scheduled.

**Closing Date:**

{a} The buyers and sellers are present at the closing along with their attornies.

{b} The deed is transfered from the sellers to the buyers and is recorded at the registry of deeds by the attorney.

* This is the date homeownership begins!!!!!!!!!!!!!!!!




## News From Cambodia

### ASEAN seen as a boost for Cambodian stability:

Phnom Penh, May 31 (Reuter)- Cambodia Saturday warmly welcomed the Association of Southeast Nations (ASEAN) decision to admit it to the group in July, and some analysts said they were hopeful the move would be a catalyst for political stability. Foreign ministers in the seven-member group decided in Kuala Lampur to admit Cambodia, Burma, and Laos at their meeting in July, not at ASEAN summit meeting in December. " oh god, that good for Cambodia" Information Minister Ieng Mouly told Reuters after hearing the news". " Now we'll be part of the region, we can play a role in the region. We can contribute and participate," he said. " It is the best news of the year," said Kao Kim Hourn, director of the Cambodian Institute for Co-operation and Peace think tank. A bitter feud between the two leaders of Cambodia's coalition government over power- sharing and other issues has lead to considerable tension and a dead lock in parliament, preventing the passing of key legistaltion needed for ASEAN membership. ASEAN comprises Brunei, Indonesia, Malaysia, the Philippines, Singapore, Thailand and Vietnam. There were suggestion in Phnom Penh that the admission of Cambodia and the other two countries might be delayed until December, partly because of the political instability. " I think it means they didn't take to consideration the internal problems," Ieng Mouly said. Neither the First priminister Prince Norodom Ranariddh nor his co-premier and political rival, Hun Sen, were immediately available for comment. But aides of both men welcomed the news that Cambodia would become a ful member of ASEAN in July. Our leaders will have to be more compromising, more flexible. Now we cannot operate in the sphere of Cambodia alone.

" Now we are in the sphere of ASEAN," said Kao Kim Hourn. It will be that the other ASEAN could enable the group to put greater pressure on Cambodia's leaders to resolved their desputes, a diplomate said. Memeberhip of the dynamic regional group could help Cambodia shed once and for all its " Killing Fields" image of death and destruction earned during the bloody 1970s Khmer Rough rule and a subsequent decade-long war, diplomats and analysts said. " Cambodian now cannot just be identified with the killing fields, all the negative images," said Kao kim Hourn. " Now it can be identified with this fast -growing, dynamic region. Cambodia is now a part of that." Official said Cambodia would reap long-term economic gains from membership in ASEAN and its free trade area, though in the short-term there would have to be some difficult restructuring, particularly in the tax system and export sector, before the financial reward began to flow.

### Mine practice blasts spark fear in Cambodia capital:

Phnom Penh, May 30 (Reuter)- A seriese of explosions on the outskirts of Phnom Penh caused near panic in the capital Friday as many people assumed that fighting between Cambodia's rival political fanctions had finally erupted, witness said. The explosions were clearly heard in the city centre, and almost immediately the street were full of frightened parents and tearful schoolchildren rushing home while merchants slammed down the shutters on their shopp, said witnesses. Heavily armed military police were soon on the street stopping cars and motorcycles and checking for weapons. " We are sorry about this, that we did not make a public announcement before. We only inform the people living in the vicinity of the training school," Information Minister Ieng Mouly told reporters. We wil find out who provoked the turmoil in the city and we will punish them," Said Ieng Mouly, who is also the president of the Cambodian Mine Action Centre that run the training school where the explosions took place. A long-running feud between the two leaders of Cambodia's coalition governement has led to fear that there could be fightingbetween the two sides. A shot was fired at a car in which co-Prime Minister Hun Sen was travelling on Wednesday evening, injuring one of his security men.




# ព័ត៌មានពីមាតុប្រទេស..........

Reuter ក្រុងវ៉ាស៊ីងតុនឌីស៊ី ថ្ងៃព្រហស្បត្តិ៍ ទី២២ ឧសភា ១៩៩៧ អ្នកស្រី Madeleine Albright អគ្គលេខាធិការសហរដ្ឋអាមេរិកមានប្រសាសន៍កាលពី ថ្ងៃព្រហស្បត្តិ៍ ២២ ឧសភាកន្លងមកនេះ ថា អ្នកស្រីនឹងអញ្ជើញ ទៅធ្វើ ទស្សនកិច្ចនៅប្រទេសវៀតណាមនិងប្រទេសខ្មែរនៅខែខាងមុខនេះ។ អ្នកស្រីមានប្រសាសន៍ទៅកាន់ព្រឹទ្ធសភាសហរដ្ឋអាមេរិកជំរាបពីដំណើរ របស់អ្នកស្រីទៅកាន់ប្រទេសទាំង២ មុនពេលអ្នកស្រីធ្វើដំណើរទៅក្រុងហុងកុងដើម្បីចូលរួមក្នុងពិ ធីបុណ្យ ប្រគល់ក្រុងហុងកុង ទៅឲ្យប្រទេសចិន វិញនៅថ្ងៃទី១កក្កដាខាងមុខនេះ។ អ្នកស្រីមានប្រសា សន៍ពីការចាប់អារម្មណ៍ពីអំពើឃោរឃៅដែលកើនឡើងក្នុងប្រទេសខ្មែររួមទាំងការបោកគ្រាប់បែក ទៅលើ ក្រុមបាតុករ កាលពីថ្ងៃទី៣០មីនាកន្លងមកនេះ។ អ្នកស្រីមានប្រសាសន៍ថាសហរដ្ឋអាមេរិកបាន ធ្វើការព្រមានដល់អ្នកដឹកនាំខ្មែរពីអំពើឃោរឃៅនេះដែលអាចបណ្តាលឲ្យប៉ះពាល់ដល់ការគាំទ្រប្រទេសខ្មែរពីសំណាក់ប្រទេសអន្តរជាតិ។ អ្នកស្រីមាន ប្រសាសន៍ថា អ្នកស្រីយល់ព្រមពីសេចក្តីសន្និ ដ្ឋានរបស់ព្រឹទ្ធសភា សហរដ្ឋម្នាក់ដែលមាន ប្រសាសន៍ថា ប្រទេសខ្មែរអាចធ្លាក់ទៅក្នុងសង្គ្រាមស៊ីវិលបាន ដែលអាចបណ្តាលឲ្យមានការពន្យាពេល ពីការបោះឆ្នោតនៅឆ្នាំ១៩៩៨ខាងមុខនេះ។ អ្នកស្រីមាន ប្រសាសន៍ថា "ខ្ញុំនឹងបញ្ជាក់ឲ្យបានច្បាស់ថាជាការសំខាន់ណាស់ដែលប្រទេសខ្មែរត្រូវធ្វើដំណើរ តាមមាគ៌ាប្រជាធិបតេយ្យ"។ អ្នកស្រីមានប្រសាសន៍បន្ថែមទៀតថាជាទស្សនកិច្ចរបស់អ្នកស្រីនឹងជួយឲ្យសហរដ្ឋអាមេរិក សំរេចពីឥរិយាបថខ្លួននៅពេលប្រជុំស្តីពីជំនួយកសាងប្រទេសខ្មែរនៅថ្ងៃទី១-២ កក្កដាខាងមុខនេះនៅក្រុងប៉ារីសនិងពីការដែលប្រទេសខ្មែរមានបំណងចង់ចូលជាសមាជិកសមា គមប្រទេសអាស៊ីនាពេលខាងមុខនេះ។ អ្នកស្រីមានប្រសាសន៍ថា "យើងត្រូវធ្វើយ៉ាងណាជួយដល់ចលនាប្រជាធិបតេយ្យក្នុងប្រទេសខ្មែរហើយថាបើការចូលរួមក្នុងសមាគមប្រទេសអាស៊ីនឹងជួយពង្រឹងចលនានេះនោះយើងនឹងជួយគាំទ្រតសំខាន់បំផុតយើងត្រូវវិភាគពីស្ថានការណ៍ក្នុងប្រទេស ខ្មែរសិន"។ អ្នកស្រីមិនបានប្រាប់ពីថ្ងៃពិតប្រាកដដែលអ្នកស្រីនឹងអញ្ជើញទៅប្រទេសខ្មែរទេ តែអ្នកស្រីប៉ាន់ស្មានថាអ្នកស្រីនឹងចាកចេញពីក្រុងសេតវិមាន នៅថ្ងៃ ទី២៨មិថុនាហើយនឹងទៅដល់ក្រុង ហុងកុងនៅថ្ងៃទី៣០មិថុនា។ លោក Warren Christopher ជាអគ្គលេខាធិការរដ្ឋ សហរដ្ឋអាមេរិកមុនអ្នកស្រី បានអញ្ជើញទៅក្រុងភ្នំពេញ និងក្រុងហាណូយនៅខែសីហា១៩៩៥កន្លងមកនេះ។

លោក បានចូលរួមក្នុងការបើកទ្វារ ស្ថានទូតសហរដ្ឋអាមេរិកាំងនៅក្រុងហាណូយហើយលោកជាអ្នកតំណា ងជាន់ខ្ពស់សហរដ្ឋធំបំផុត ដែលបានអញ្ជើញទៅកាន់ប្រទេសវៀតណាមដែលជាសត្រូវ។

*Xinhua ក្រុងបាងកក ថ្ងៃ ព្រហស្បត្តិ៍ ទី២២ ឧសភា ១៩៩៧ លោករដ្ឋមន្ត្រីក្រសួងការបរទេសថៃ មានប្រសាសន៍ថា ប្រទេសថៃប្រុងប្រៀបនឹងស្ថាបនាផ្លូវជាតិតភ្ជាប់ពីខេត្តសូរិន ប្រទេសថៃទៅកាន់ខេត្តសៀមរាប ប្រទេសខ្មែរក្នុងពេលឆាប់ៗខាងមុខនេះ។ លោក ពីតាក់ អ៊ិនត្រាវីធីយ៉ានុន រដ្ឋមន្ត្រីក្រសួងការបរទេសថៃ មានប្រសាសន៍ ថាលោកនឹងជំរាបអាជ្ញាធរខ្មែរ ឲ្យដឹងថា ប្រទេសថៃ ត្រៀមខ្លួនរួចស្រេចដើម្បីស្ថាបនាផ្លូវជាតិនេះក្នុងពេលទស្សនកិច្ចរបស់លោក ចំនួន ២ថ្ងៃទៅកាន់ប្រទេសខ្មែរ ចាប់តាំង ពីថ្ងៃ ព្រហស្បត្តិ៍ នេះតទៅ។ លោកមានប្រសាសន៍ថាប្រទេស ថៃនឹង ចេញប្រាក់ស្ថាបនាផ្លូវជាតិចំងាយ ១៦៥គីឡូម៉ែត្រនេះ ឃោលទៅតាមសំណូមពររបស់ទ្រង់ រណ្ណរិទ្ធ។ គំរោងស្ថាបនាផ្លូវជាតិពីប្រទេសថៃទៅកាន់ប្រទេសខ្មែរនេះ ជាផ្នែកមួយនៃ គំរោងស្ថាបនាប្រព័ន្ធផ្លូវជាតិរវាង ប្រទេសថៃ, លាវ, ខ្មែរនិង ប្រទេសវៀត ណាម។ លោក ចាវ៉ាលិតយ៉ុងចៃយុទ្ធអគ្គ រដ្ឋមន្ត្រីថៃចាប់ផ្តើមប្រកាសពីគំរោងស្ថាបនា ប្រព័ន្ធផ្លូវជាតិ នេះនៅពេលលោកអញ្ជើញ ទៅក្រុងភ្នំពេញ នៅថ្ងៃទី ២១មិថុនាខាងមុខនេះ មួយថ្ងៃក្រោយពេលលោក អញ្ជើញ ទៅកាន់ ក្រុងវៀងចាន់មក។*

CAP

Cambodian Arts, & Poetry



## គ្រូ និង សិស្ស (×)

សិល្បៈ គឺជាស្នាដៃរបស់មហាជន ។

សិល្បៈ ជាការងារដោយផ្ទាល់រវាងមនុស្ស និងមនុស្ស, មនុស្ស និង ធម្មជាតិ,មនុស្ស និងវាសនាអនាគតរបស់ខ្លួន ។

សិល្បៈ ជាកញ្ចក់សម្រាប់ឆ្លុះធម្មជាតិ និងឆ្លុះសង្គម ។

សិល្បៈ ជាភស្តុតាងដែលមនុស្សស្គាល់ធម្មជាតិ ស្គាល់សង្គម និងស្គាល់ពីសតិអារម្មណ៍របស់មនុស្ស ។

សិល្បៈ គឺជាការបកប្រែរបស់ធម្មជាតិពិតៗ-រស់រវើកនៅជុំវិញខ្លួនប្រកបដោយចិត្តរំភើប និងមនុស្សធម៌ជាទីបំផុត ។

សិល្បៈ មិនមែនជាមុខរបរទេ តែគឺជាទេពកោសល្យ ។

សិល្បៈ ឬស្នាដៃ គឺជាការប្រដេញទៅរកអាថ៌កំបាំងទាំងឡាយ ដែលមាននៅក្នុងធម្មជាតិ និងក្នុងសង្គម ។

សិល្បៈ គឺជាទ្រង់ទ្រាយរបស់សញ្ញាណសង្គម ។ អ្វីដែលល្អនៅក្នុងធម្មជាតិ មិនមែនសុទ្ធតែជាសិល្បៈទាំងអស់ទេតែអ្វីដែលជាសិល្បៈសុទ្ធតែល្អទាំងអស់ ។

កត្តាពីរដែលល្អ នាំឲ្យសិល្បៈរីកចំរើន ស្ថិតស្ថេរ គឺៈ ទីមួយ ត្រូវមានការរិះគន់ (តាមមូលដ្ឋានទ្រឹស្តី) និងទីពីរ គឺ ត្រូវមានការលើកទឹកចិត្ត ។

អ្នកសរសេររឿងល្ខោន គឺជាអ្នកលេងល្បែងបញ្ញាមួយរូបដ៏ពូកែបំផុត ។

(×)ដកស្រង់ចេញពីសៀវភៅៈ គ្រូ និង សិស្ស

(ស្នាដៃសំរាំងនិងបទពិសោធន៍នៃព្រឹទ្ធាចារ្យ ឆេង ផុន)

ចងក្រងដោយៈ គឹម ពេជ្រពីរនន់ បរិញ្ញាប័ត្រសិល្បៈ

CAPសិល្បៈកំណាព្យខ្មែរ



## POSTCARD FOR FATHER'S DAY

<u>សេចក្តីសំបុត្រៈ</u> ជូនចំពោះលោកឪពុក

កូនធំដឹងក្តី យល់នូវរស្មី អ្វីជាជីវិត
ដោយសារូបអ្នក ខំទាំងកាយចិត្ត ការពារស្នេហ៍ស្និទ្ធ
ចិញ្ចឹមកុលបុត្រ ។

ក្នុងថ្ងៃបុណ្យខួប ទិវាគម្រប់ គុណាបរិសុទ្ធ
នៃបិតាថ្លៃ ធ្ងន់គ្មានកំណត់ កូនផ្ញើរសំបុត្រ
ឲ្យលោកយល់ចិត្ត។

ច្រើនឆ្នាំកន្លង លោកបានគ្រប់គ្រង រក្សាជីវិត
ដោយក្តីសន្តោះ តាមធម៌ប្រណិត ទោះនៅឆ្ងាយជិត
តែមិនភ្លេចកូន ។

លោកជាបិតា ស្រោចស្រង់គ្រួសារ ចាកភាពសាបសូន្យ
ចាកភពសង្គ្រាម ដឹកដៃនាំកូន នាំរត់និងលូន
ស្វែងទ្រនុំថ្មី។

ទឹកដីបរទេស លោកតែងត្រិះរិះ ដាស់តឿនបុត្រថ្លៃ
ឲ្យខំរៀនសូត្រ ចំណេះប្រពៃ ជាកាំរស្មី
ចាំងជីវិតផង ។

គុណរបស់អ្នក ដែលកូនជំពាក់ ពិបាកនិងសង
តែកូនផ្ញើរពាក្យ អរគុណកន្លង លោកជារៀមច្បង
ដែលកូនគោរព ។



និពន្ធដោយ សាទ ប៊ុនរិទ្ធ

2015-1014.038



NON-PROFIT ORG
US POSTAGE
**PAID**
LOWELL, MA 01853
PERMIT NO. 1010

**Cambodian American League of Lowell**
**79 High Street**
**Lowell, MA 01852**
**(508) 454-3707**

TO: Laurie Kalb/ Boott Mills Museum
New England Folk Life Center
400 Foot off John St.
Lowell, MA 01852

## CAP
Cambodian Arts,& Poetry

### Drop By Drop

Little mists of dew,
Little drops of water,
Make the greatest field
And the landscape greener.

This scenery makes me recall
the Cambodian palm tree,
Their long flowers hang down like sticks,
Where farmers climbs up with bamboo container.

Drop by drop that palm juice,
Drips into the container,
It will fill it up,
And then farmer will make it into sugar.

One page of book,
One new word each day,
Can gain knwoledge
And build your life always.

Tick! Tick! every second,
Tick! Tick ! every minute,
Add up to an hour
And days come by faster than you thought.

Bunrith Edward Sath
Lowell @ 05-23-97

